ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទ សហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រ សម្រាប់រយៈពេល ០៥ ឆ្នាំ (២០១៧ - ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ សាមគ្គីអភិរក្សស្ទឹងកំបុត្រ |
| ភូមិ | ៖ ព្រៃព្រះ |
| ភូមិ | ៖ ចុងព្រៃ |
| ភូមិ | ៖ ត្នោត |
| ឃុំ | ៖ កំពង់ស្វាយ |
| ស្រុក | ៖ កំពង់ស្វាយ |
| ខេត្ត | ៖ កំពង់ធំ |

ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៧

# មាតិកា


១.ស្ថានភាពទូទៅ ........ ៤

២.អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម ........ ៤

ក.ប្រជាពលរដ្ឋ ........ ៤

ខ. មុខរបរ ........ ៥

៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ........ ៦

ក.ទីតាំង ........ ៦

ខ.ដែននេសាទ ........ ៦

ខ.១.ស្ទឹង ........ ៦

ខ.២.បឹង ........ ៦

ខ.៣.អូរ ........ ៧

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៧

ឃ. ធនធានជលផល ........ ៨

១.ប្រភេទត្រី ........ ៩

២.ប្រភេទវារីសត្វ ........ ៩

៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........ ៩

៤.ការធ្វើនេសាទ ........ ៩

ក.អ្នកនេសាទ ........ ១០

ខ.ឧបករណ៍នេសាទ ........ ១០

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ១២

៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២

ក.ទស្សនៈវិស័យ ........ ១២

ខ.គោលបំណង ........ ១២

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ១២

គ.២. ផែនការកែលម្អដែននេសាទ ........ ១៤

គ.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ១៥

គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ១៦

គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១៧

គ.៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........ ១៨

គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ........ ២០

គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ........ ២០

គ.៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ២១

គ.១០.ផែនការផ្សព្វផ្សាយពីច្បាប់ផលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ.............................. ២២
គ.១១.ផែនការបង្កើតស្នាក់ការសហគមន៍ ............................................................... ២២
គ.១២.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ............................................ ២៣
គ.១៣.ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលប្រជុំផ្សេងៗ ........................... ២៣
ឃ. យុទ្ធសាស្ត្រ.......................................................................................................... ២៤

**៦.ឧបសម្ពន្ធ**

ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ ២០១៧-២០២២
ឧបសម្ពន្ធ ៖តារាងកម្មវិធីការងារឆ្នាំ ២០១៧-២០២២

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផល បានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ឱ្យចូលរួមចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឲ្យធនធានជលផលឲ្យប្រសើរឡើង ក្នុងមូលដ្ឋានរបស់ខ្លួន ។ ភូមិទាំងបីនេះ ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងគុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជំនាញជលផល និងសហការពីអាជ្ញធរដែនដី ។ ដូចេនះ សហគមន៍នេសាទ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ ២០១២ ដល់ ២០១៤ ព្រមទាំងត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨។ សហគមន៍នេសាទសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រ ត្រូវបានរៀបចំបោះឆ្នោតឡើងវិញលើកទី១ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០០៩ ព្រមទាំងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រ នឹងធ្វើបច្ចុប្បន្នភាព និងរៀបចំលើកទី ២ នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៧ ដោយមានចូលរួមពីសមាជិកគណៈកម្មសហគមន៍នេសាទ ប្រជាពលរដ្ឋ មេភូមិព្រៃព្រះ មេភូមិចុងព្រៃ មេភូមិត្នោត និងក្រុមប្រឹក្សាកំពង់ស្វាយ ជាពិសេសបានការគាំទ្របច្ចេទេសពីរដ្ឋបាលជលផលថ្នាក់កណ្តាល និងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលកំពង់ធំ និងគាំទ្រថវិកា អង្គការ FAO។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតចំនួន ០១ អណ្តត្តិ រហូតមកដល់ពេលបច្ចុប្បន្ន ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ ។ ទន្ទឹមនឹងនេះ គណៈកម្មសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារ និងទស្សនកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗខ្លះ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយចីរភាព និងសមធម៌។

## ២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំនេះមានចំនួន ១២ ភូមិ ប្រជាពលរដ្ឋសរុបចំនួន ៣២៥៤ គ្រួសារ និង ប្រជាពលរដ្ឋសរុបចំនួន ១៥០៧២ នាក់ ក្នុងស្ត្រីចំនួន ៧៦២ នាក់ ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ២៩២ គ្រួសារ ។ ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងឃុំកំពង់ស្វាយបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ៤៦២ គ្រួសារ និងស្ថានភាពក្រីក្រ ២ មានចំនួន ៤៦៤ គ្រួសារ ដែលសរុបចំនួន ៩២៦ គ្រួសារ ។ ដោយឡែកសហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រគ្រប់ដណ្តប់ចំនួន ៣ ភូមិដែល

មានឈ្មោះ ភូមិព្រៃព្រះ ភូមិចុងព្រៃ និងភូមិត្នោត ដោយមានប្រជាពលរដ្ឋសរុបចំនួន ៧៣១ គ្រួសារ នាក់ ហើយប្រជាពលរដ្ឋសរុបចំនួន ៣.៣២៤ នាក់ ក្នុងនោះស្ត្រីមានចំនួន ២០១៣ នាក់។ ដូច្នេះ ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានចំនួន ៦៣១ គ្រួសារ ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ៧២ គ្រួសារ ហើយមានមនុស្សដែលជាសមាជិកសហគមន៍នេសាទចំនួន១២៩៤ នាក់ ក្នុងនោះស្ត្រីចំនួន៧៣៥នាក់ ។ ដូច្នេះ ចំនួនសមាជិកសហគមន៍នេសាទមានប្រមាណ ១៩ ភាគរយ បើប្រៀបធៀបជាមួយប្រជាពលរដ្ឋគិតជាគ្រួសារនៅក្នុងឃុំនេះ ។

ដូច្នេះ ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានចំនួន ៦៣១ គ្រួសារ ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ៧២ គ្រួសារ ហើយប្រជាជនជាជនជាតិខ្មែរ ហើយគោរពព្រះពុទ្ធសាសនាដែលមានស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅភូមិព្រៃព្រះ ភូមិចុងព្រៃ និងភូមិត្នោតក្នុងឃុំកំពង់ស្វាយ បានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ១០២ គ្រួសារ និងស្ថានភាពក្រីក្រ ២ មានចំនួន ១១៣ គ្រួសារ ដែលសរុបចំនួន ២១៥ គ្រួសារ
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៨៤ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ១២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស ៣១ នាក់ ក្នុងនោះស្ត្រីមានចំនួន ១១ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ២៨ នាក់ ក្នុងនោះកុមារីមានចំនួន ១៧ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣៧ នាក់ក្នុងនោះស្ត្រីមានចំនួន ២៧ នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ២២ នាក់ ក្នុងនោះស្ត្រីមានចំនួន ១៦ នាក់
- សាលារៀនបឋមសិក្សាសុខាល័យមានចំនួន ២ខ្នង ដែលមាន ០៦ បន្ទប់ មានសិស្សសរុបចំនួន ១៩២ នាក់ ក្នុងនោះកុមារីមានចំនួន ៩៤ នាក់ ។
- ចំនួនគ្រួសារដែលកើតមេរោគអេដស៍មានចំនួន ៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ០៤ នាក់។
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំកំពង់ស្វាយ នៅក្នុងសហគមន៍នេសាទនេះបានបង្ហាញថា ៨០ នាក់ ដែលមិនចេះអក្សរ ក្នុងនោះស្ត្រីចំនួន ៦៥ នាក់ ។

### ខ.សេដ្ឋកិច្ចសង្គម

តាមរបាយការណ៍ និងឯកសារព័ត៌មានឃុំឆ្នាំ ២០១៦ បានបញ្ជាក់ថា នៅក្នុងសហគមន៍នេះ មានប្រពលរដ្ឋសរុបចំនួន ៧៣១ គ្រួសារ ដែលបានពឹងផ្អែកលើការធ្វើស្រែជាចំបង ការចិញ្ចឹមសត្វ ការនេសាទ និងលក់ដូរ រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា ផ្តល់ចំណីត្រី និងលក់ដូរ ជាដើម។ កន្លងមក នៅក្នុងសហគមន៍នេសាទសាមគ្គីអភិវឌ្ឍស្ទឹងកំបុត្រ បានបង្កើតក្រុមសន្សំចំនួន ០៣ ក្រុម និងការចិញ្ចឹមត្រីក្រាញ់តាមស្រះដែលជួយគាំទ្របន្ថែមដល់មុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ដែលជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទនេះ ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

- អ្នកធ្វើស្រែ ចិញ្ចឹមសត្វ និងនេសាទ ៧០១ គ្រួសារ
- អ្នកធ្វើស្រែ ចិញ្ចឹមសត្វ និងអ្នកចិញ្ចឹមត្រីក្រាញ់តាមស្រះចំនួន ៣ គ្រួសារ
- អ្នកលក់ដូរ ធ្វើស្រែ នេសាទ និងចិញ្ចឹមសត្វ ២៧ គ្រួសារ

ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិតដោយពឹងផ្អែកលើការធ្វើស្រែ ការចិញ្ចឹមសត្វនេសាទ ការចិញ្ចឹមត្រីក្រាញ់តាមស្រះ និងលក់ដូរមានចំនួនសរុប ៧៣១ គ្រួសារ ។ ដោយឡែកក្នុងចំណោមគ្រួសារទាំងបីភូមិនេះមានប្រជាពលរដ្ឋធ្វើជាកម្មករក្រៅប្រទេស និងក្នុងប្រទេសចំនួន ៣០២ និងគ្រួសារធ្វើជាគ្រូបង្រៀន ៣៥ នាក់ ក្នុងនោះស្ត្រីចំនួន ១៨ នាក់។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក.ទីតាំង

សហគមន៍នេសាទនេះមានទីតាំងស្ថិតក្នុងភូមិព្រៃព្រះ ភូមិចុងព្រៃ និងភូមិត្នោតដែលជាដែននេសាទសាធារណៈរបស់រដ្ឋក្នុងខេត្តកំពង់ធំ ។ កន្លែងនេសាទសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រមានទំហំ ៤៣ ហិកតា ហើយមានកន្លែងអភិរក្សពូជត្រីសំខាន់ៗចំនួន ០២ កន្លែង គឺ អន្លង់តាផន មានទំហំប្រហែល ១,៤៨ ហិកតា និង អន្លង់ស្វាយឈ្លបមានទំហំប្រហែល ១.២០ ហិកតា ។ ទីតាំងទាំងនេះ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ដូចនេះ សហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹងឃុំជ័យ
- ខាងត្បូងទល់នឹងព្រំប្រទល់ភូមិពាមចាស់
- ខាងកើតទល់នឹងឃុំប្រសាទសំបូរណ៍ និង
- ខាងលិចទល់នឹងឃុំជ័យ។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រ មានវិសាលភាពដែលគ្រប់ដណ្តប់លើកន្លែងអភិរក្សពូជត្រីសំខាន់ៗ អូរ ស្ទឹង និងបឹងសំខាន់ៗមួយចំនួនដូចជា៖

#### ខ.១.ស្ទឹង

| ល.រ | ឈ្មោះស្ទឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ស្ទឹងកំបុត | ២៦.២០ | ខែ ០១ - ខែ ១២ |
| សរុប | | ២៦.២០ | |

#### ខ.២ បឹង

| ល.រ | ឈ្មោះបឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងថ្លោល | ៣ | ខែ ១០ - ខែ ០១ |
| ២ | បឹងអន្លែងជាប់ | ១ | ខែ ១០ - ខែ ១២ |
| ៣ | បឹងរ៉ាកខាក | ១.២០ | ខែ ១២ - ខែ ០៤ |
| ៤ | បឹងភ្លៅ | ៦.១០ | ខែ ១០ - ខែ ០៤ |
| ៥ | បឹងឈូកឆ្អោក | ១ | ខែ ០១ - ខែ ១២ |
| ៦ | បឹងតាងង់ | ១,៨ | ខែ ០១ - ខែ ១២ |

**ខ.៣.អូរផ្សេងៗដែលមិននៅក្នុងផែនទីសហគមន៍**

កន្លែងនេសាទសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រ ត្រូវបានរកឃើញអូរសំខាន់ៗបន្ថែមមួយចំនួនដែលមិននៅក្នុងផែនទីរបស់សហគមន៍នេសាទមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអូរ | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | អូរសំរោង | ០.៩៦ | ខែ ១០ - ខែ ១១ |
| ២ | អូរអាចម៍ | ១.៦ | ខែ ១០ - ខែ ១១ |
| ៣ | អូរតាហែម | ០.១២ | ខែ ១០ - ខែ ១១ |
| ៤ | អូរដើមសំរោង | ០.៣៧ | ខែ ១០ - ខែ ១១ |
| ៥ | អូព្រៃព្រះ | ០.២៧ | ខែ ១០ - ខែ ១១ |
| ៦ | អូរឡូង | ០.១៧ | ខែ ១០ - ខែ ១១ |
| ៧ | អូរអណ្តែងដាច់ | ៣.៩០ | ខែ ០៩ - ខែ ១១ |
| ៨ | អូរតាកោះ | ១.៥០ | ខែ ១០ - ខែ ១១ |
| ៩ | អូរអន្ទេប | ០.៩០ | ខែ ០៩ - ខែ ១១ |
| ១០ | អូរស្វាយ | ២,២០ | ខែ ១០ - ខែ ១១ |

ដូច្នេះ អូរសំខាន់ៗមួយចំនួនដែលមិននៅក្នុងផែនទីរបស់សហគមន៍នេសាទនេះមានទំហំសរុបចំនួន ១១,៩៩ហិកតាដែលមិនគិតបញ្ចូលក្នុងទំហំសហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រចំនួន ៤៣ ហិកតា ទេ។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទ បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺ អន្លង់តាផន មានទំហំប្រហែល ១,៤៨ ហិកតា និងអន្លង់ស្វាយឈ្លប មានទំហំប្រហែល ១.២០ ហិកតា ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអន្លង់ | ទំហំជា ហត | ការអភិរក្ស |
|---|---|---|---|
| ១ | អន្លង់តាផន | ១.៥០ | កន្លែងអភិរក្សត្រីមេពូជ |
| ២ | អន្លង់ស្វាយឈ្លប | ១.២០ | កន្លែងអភិរក្សត្រីមេពូជ |

**ឃ.ធនធានជលផល**

**១.ប្រភេទត្រី៖**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ។ តាមការបង្ហាញពីសហគមន៍បានឱ្យដឹងថា ពេលបច្ចុប្បន្ន ធនធានជលផលបានថយចុះជាពិសេស ក្នុងឆ្នាំ ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យបឹង និងព្រែករីងរាក់ ហើយធ្វើឱ្យប្រភេទត្រីមេពូជត្រូវបាននេសាទយកស្ទើរតែទាំងអស់ ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍ធនធានជលផលក្នុងសហគមន៍នេសាទមានដូចជា៖

**ឃ.១.ប្រភេទត្រី៖**

ក្នុងសហគមន៍នេសាទមានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីគ្រុំ ត្រីឆ្ពិន ត្រីកន្ធប់ ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទីង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្ពោ ត្រីអណ្តែង ត្រីឆ្តួញ ត្រីកន្ទង ត្រីឆ្ពោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្លៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីពួលុង ត្រីស្រកាក្តាម ត្រីគល់រាំង ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ ត្រីឆ្លាំង ។ល។

**ឃ.២.ប្រភេទវារីសត្វ**

ក្នុងសហគមន៍នេសាទ មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់ កង្កែប ហឹង តឺង្កក់ ពស់ខ្សែគោ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ គេ សំពោច ។ល។

**ឃ.៣.ប្រភេទបក្សី**

ក្នុងសហគមន៍នេសាទ មានប្រភេទបក្សីដូចជា៖ សត្វទោម សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអុត សត្វសេក សត្វលលក សត្វចាប សត្វនាលខ្យង សត្វក្រសា ។ល។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**

ក្នុងសហគមន៍នេសាទ មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអ្សូ ដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយូន ដើមស្នាចទឹក ដើមកណ្តាប់ចង្អេរ ដើមរំដេញ ដើមបន្លាស្វិត ដើមច្រកែង ។ល។

## ៤.ការធ្វើនេសាទ

នេសាទជាមុខរបរបន្ទាប់ពីការធ្វើស្រែ និងចិញ្ចឹមសត្វសម្រាប់ការចិញ្ចឹមជីវិតរបស់សហគន៍នេសាទ និងផលត្រីដែលចាប់បានពីកន្លែងនេសាទសហគមន៍ ត្រូវបានប្រើប្រាស់ជាម្ហូបអាហារប្រចាំថ្ងៃ និងផលត្រីខ្លះត្រូវបានធ្វើជាប្រហុកហូបសម្រាប់គ្រួសារ ។ ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍នេះបានប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារ ក្នុងការនេសាទ ប៉ុន្តែការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍ដែលបានរៀបចំសម្រាប់ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១០ ។ ទោះបីជាយ៉ាងនេះក្តី នៅមានជនល្មើសខ្លះ បានប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅលើកន្លែងនេសាទសហគមន៍ ជាពិសេស ការប្រើប្រាស់ឧបករណ៍ឆក់នៅតាមបឹង អូរ និងស្ទឹង ហើយប្រភេទត្រីមេពូជបាននេសាទដោយជនល្មើស ។

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍នេសាទ បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍មានដូចខាងក្រោម៖

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៦៣១ គ្រួសារ មានចំនួន ១២៩៤ នាក់ ក្នុងនោះស្ត្រីមានចំនួន ៧៣៥ នាក់ ។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍នេះមានចំនួន ១០០ គ្រួសារ ដែលមានមនុស្សសរុបចំនួន ២៦៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ១១៥ នាក់ ។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មានប្រហែល ១០ គ្រួសារ ក្នុង១ឆ្នាំ ។

## ៤.ខ.ឧបករណ៍នេសាទ

កន្លងមក នៅរដូវបើកនេសាទ ប្រជាជននៅក្នុងសហគមន៍នេសាទ និងអ្នកខាងក្រៅ តែងតែធ្វើនេសាទ ដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ មងរាយ សំណាញ់ សន្ទូចរនង លបដាក់លាន់ ទ្រូ និងអញ្ចងអូស ។ល។ ដូចនេះផងដែរ សមាជិក និងគណៈកម្មការសហគមន៍បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទ ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេស សមាជិក និងគណៈកម្មការសហគមន៍នសាទ ទាមទារសមត្ថកិច្ចជំនាញជលផល ធ្វើការផ្សព្វផ្សាយច្រើនដងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងអ្នកនសាទខាងក្រៅ លើប្រភេទឧបករណ៍នេសាទ ដែលហាមឃាត់ដូចជា៖ ឧបករណ៍ឆក់ត្រី ។ល។ ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់ក្នុង សហគមន៍នេះដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៤៥ម x២,៥ម x០,០៣៥ម | ពីខែ ១២ ដល់ ខែ ០១ |
| ២ | សំណាញ់ | សំណាញ់ | ១ សំណាញ់ | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | សន្ទូចរនង | ផ្លែ | ២០០ ផ្លែ | ពីខែ ០៧ ដល់ ខែ ១២ |
| ៤ | លប | លប | ៣ លប | ពីខែ ០៧ ដល់ ខែ ១២ |
| ៥ | ដាក់លាន់ | លាន់ | ៦០លាន់ | ពីខែ ១០ ដល់ ខែ ០១ |
| ៦ | ទ្រូ | ទ្រូ | ៣ ទ្រូ | ពីខែ ១០ ដល់ ខែ ០១ |
| ៧ | អញ្ចងអូស | ម៉ែត្រ | ៤ម x២,៥ម x០,០៣៥ម | ពីខែ ០១ ដល់ ខែ ០៤ |

| ប្រភេទទូក | ចំនួន(ទូក) | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|
| ទូកអុំ ឬទូកចែវ | ៨០ | ៨០ | |
| សរុប | ៨០ | ៨០ | |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

កន្លងមក នៅរដូវបើកនេសាទ អ្នកខាងក្រៅប្រហែលចំនួន ១០ គ្រួសារ តែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ មងរាយ សន្ទូចរនង ដាក់លាន់ ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងឧបករណ៍នេសាទ និងទូក របស់អ្នកនេសាទខាងក្រៅដែលប្រើប្រាស់ក្នុងសហគមន៍នេះដូចជា៖

| ប្រភេទឧបករណ៍ | ឯកតា | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|
| មងរាយ | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ពីខែ ៨ ដល់ ខែ ៩ |
| សន្ទូចរនង | ផ្លែ | ២០០ ផ្លែ | ពីខែ ០៧ ដល់ ខែ ១២ |
| ដាក់លាន់ | លាន់ | ៦០ លាន់ | ខែ ០១ ដល់ ខែ ០២ |

| ប្រភេទទូក | ចំនួន(គ្រឿង) | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|
| ទូកអុំ ឬទូកចែវ | ១០ | ១០ | |
| សរុបរួម | ១០ | ១០ | |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យម ប្រចាំគ្រួសារ (គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៨៥ | ៣០៦ | ៣៩១ |
| ក្ដាម ខ្យង ខ្ចៅ និងលៀស | ៧,៥ | ៨,៥ | ១៦ |
| អន្ទង់ | ៣០ | ៦០ | ៩០ |
| សរុប | ៩៣,៥០ | ៤០៤,៥០ | ៤៩៧ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ឡើង និងព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍ ចំរុះដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

#### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និង រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងកន្លែងនេសាទ ដោយដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៤៥ម x២,៥ម x០,០៣៥ម | ពីខែ ១២ ដល់ ខែ ០១ |
| ២ | សំណាញ់ | សំណាញ់ | ១ សំណាញ់ | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | សន្ទូចរនង | ផ្លែ | ២០០ ផ្លែ | ពីខែ ០៧ ដល់ ខែ ១២ |
| ៤ | លប | លប | ៣ លប | ពីខែ ០៧ ដល់ ខែ ១២ |

| | | | | |
|---|---|---|---|---|
| ៥ | ដាក់លាន់ | លាន់ | ៦០លាន់ | ពីខែ ១០ ដល់ ខែ ០១ |
| ៦ | ទ្រូ | ទ្រូ | ៣ ទ្រូ | ពីខែ ១០ ដល់ ខែ ០១ |
| ៧ | អញ្ចាំងអួស | ម៉ែត្រ | ៤ម x២,៥ម x០,០៣៥ម | ពីខែ ០១ ដល់ ខែ ០៤ |

| ប្រភេទទូក | ចំនួន(គ្រឿង) | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|
| ទូកអុំ ឬទូកចែវ | ១០ | ១០ | |
| សរុប | ១០ | ១០ | |

នៅរដូវបើកនេសាទ អ្នកខាងក្រៅត្រូវបានធ្វើការប៉ាន់ប្រមាណប្រហែលចំនួន ១០ គ្រួសារ តែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ មងរាយ សន្ទូចរនង ដាក់លាន់ ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងឧបករណ៍នេសាទ និងទូករបស់អ្នកនេសាទខាងក្រៅដែលប្រើប្រាស់ក្នុងសហគមន៍នេះដូចជា៖

| ប្រភេទឧបករណ៍ | ឯកតា | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|
| មងរាយ | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ពីខែ ៨ ដល់ ខែ ៩ |
| សន្ទូចរនង | ផ្លែ | ២០០ ផ្លែ | ពីខែ ០៧ ដល់ ខែ ១២ |
| ដាក់លាន់ | លាន់ | ៦០ លាន់ | ខែ ០១ ដល់ ខែ ០២ |

| ប្រភេទទូក | ចំនួន(គ្រឿង) | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|
| ទូកអុំ ឬទូកចែវ | ១០ | ១០ | |

| ល.រ | ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួនគ្រួសារ |
| ១ | ស្ទឹងកំបុត | ខែ០១-ខែ១២ | មង សំណាញ់ សន្ទូច លប អញ្ចាំងអួស | ២៦.២០ | ២០០ |
| ២ | បឹងផ្ទោល | ខែ១០-ខ០ខែ១ | មង សន្ទូចលាន់ លបទ្រូ អញ្ចាំងអួស | ៣ | ៣០ |
| ៣ | បឹងអន្លែងជាប់ | ខែ១០-ខែ១២ | មង សន្ទូចលាន់ លបទ្រូ អញ្ចាំងអួស | ១ | ២៥ |
| ៤ | បឹងរ៉ាកខាក | ខែ១២-ខែ០៤ | មង សន្ទូចលាន់ លបទ្រូ អញ្ចាំងអួស | ១.២០ | ៤០ |
| ៥ | បឹងភ្នៅ | ខែ១០-ខែ០៤ | មង សន្ទូចលាន់ លបទ្រូ អញ្ចាំងអួស | ៦.១០ | ៥០ |
| ៦ | បឹងឈូកឆ្មោក | ខែ០១-ខែ១២ | មង សន្ទូចលាន់ លបទ្រូ អញ្ចាំងអួស | ១ | ១០ |

| | | | | | |
|---|---|---|---|---|---|
| ៧ | បឹងតាងង់ | ខែ០១-ខែ១២ | មង សន្ទូចលាន់ លបទ្រូ អញ្ចងអួស | ១,៨ | ៤០ |
| ៨ | អូរសំរោង | ខែ១០-ខែ១១ | លប ទ្រូ សន្ទូច | ០.៩៦ | ៤ |
| ៩ | អូរអាចម៍ | ខែ១០-ខែ១១ | លប ទ្រូ សន្ទូច | ១.៦ | ៦ |
| ១០ | អូរតាហែម | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ០.១២ | ៣ |
| ១១ | អូរដើមសំរោង | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ០.៣៧ | ២ |
| ១២ | អូព្រៃព្រះ | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ០.២៧ | ២៥ |
| ១៣ | អូរឡុង | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ០.១៧ | ៣ |
| ១៤ | អូរអណ្ដែងជាប់ | ខែ០៩-ខែ១១ | លបទ្រូ សន្ទូច | ៣.៩០ | ២០ |
| ១៥ | អូរតាកោះ | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ១.៥០ | ៤ |
| ១៦ | អូរអន្ទេប | ខែ០៩-ខែ ១១ | លបទ្រូ សន្ទូច | ០.៩០ | ៣០ |
| ១៧ | អូរស្វាយ | ខែ១០-ខែ១១ | លបទ្រូ សន្ទូច | ២,២០ | ៦ |

**ឥ.២.ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាង គណៈកម្មការសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុម សម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្ដាល បានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រមានសភាពប្រែប្រួលខ្លះ ដែលបណ្ដាលមកពីកត្តាមនុស្ស និងធម្មជាតិដូចជាបឹង អូរ និងស្ទឹង ដែលបានរីងរាក់ដែលបណ្ដាលមកពីការហូរច្រោះដោយសារការកាប់ទន្រ្ទាញព្រៃលិចទឹកនៅតាមមាត់បឹង អូរ និងស្ទឹង ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឲ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| **ឈ្មោះដែននេសាទ** | **ទំហំ** | **ទំហំដែលត្រូវកែលំអ** | **សកម្មភាព** | **ថ្ងៃខែឆ្នាំចាប់ផ្ដើម** | **ថ្ងៃខែឆ្នាំបញ្ចប់** |
|---|---|---|---|---|---|
| ដែនកាស្ដារបឹងភ្លៅ | ៦,១០ ហាត | ២ ហាត | ធ្វើការសិក្សា | ខែតុលា ២០២០ | ខែធ្នូ ២០២០ |
| | | | ការស្ដារបឹងភ្លៅ | ខែមករា ២០២១ | ខែធ្នូ ២០២១ |

**ឥ.៣ ផែនការរៀបចំកន្លែងអភិរក្ស**

សហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្រ បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺអន្លង់តាជន និងអន្លង់ស្វាយឈ្លប ដែលជាកន្លែងមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទនេះ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ

- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត និងពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិសហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត្របានបញ្ជាក់ថា៖ កន្លែងអភិរក្សអន្លង់តាផន និងអន្លងស្វាយឈ្លប គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សដែលសមាជិកសហគមន៍នេះ មានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផលដើម្បីធានានូវប្រសិទ្ធនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| អន្លង់តាផន | ១.៥០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០២២ |
| អន្លង់ស្វាយឈ្លប | ១.២០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលស៊ីម៉ង់ចំនួន ៥០ បង្គោល<br>• ផ្សព្វផ្សាយ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០២២ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹកមានគ្របដណ្តប់លើដែននេសាទសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រ ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រករស់នៅ បង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឲ្យនៅគង់វង្សយូរអង្វែងក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វគ្រប់ប្រភេទឲ្យសំបូរឡើងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិសហាគមន៍នសាទ បានគ្រប់គ្រងព្រៃលិចទឹក និងកន្លែងប្រើប្រាស់ ដោយផ្អែកតាមផែនទីសហាគមន៍នេសាទ។ ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក។

ខាងក្រោមនេះ ជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍សាមគ្គីអភិរក្សស្ទឹងកំបុត្រមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំ ហត | ប្រភេទកូនឈើ ដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅបឹងផ្ដោល | ១,៥ | រាំង ផ្ដោល ត្នួរ និង ច្រកែង ។ល។ | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ៥/៥/១៨ | ៦/៥/១៨ |
| | | | • រៀបចំកូនឈើ | ១៥/៦/១៨ | ១៧/៦/១៨ |
| | | | • ពីធីដាំកូនឈើ និងដាក់ស្លាកសញ្ញា | ២០/៦/១៨ | ២២/៦/១៨ |
| | | | • ថែរក្សា និងការពារ | ២០/៦/១៨ | ១០/១២/១៨ |
| ថែរក្សានិងការពារព្រៃលិចទឹក | ៥ | ព្រៃលិចទឹកគ្រប់ប្រភេទ | • ផ្សព្វផ្សាយការគ្រប់គ្រងព្រៃលិចទឹក | ៣០/៦/១៨ | ៣០/១២/២២ |
| | | | • ដាក់ស្លាកសញ្ញាការពារ | | |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

## គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរ មួយបន្ថែមរបស់ប្រពលរដ្ឋនៅក្នុងសហគន៍នេះ ។ជាទូទៅ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមស្រះមានដូចជា៖ ត្រីអណ្ដែង និងត្រីក្រាញ់ ។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឱ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីក ចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក កសក ស្ដីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្ដោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ជាក់ស្ដែង សហគមន៍នេសាទនេះ បានចិញ្ចឹមត្រីតាមស្រះដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីក្រាញ់ និងត្រីអណ្ដែង ពីព្រោះសហគមន៍នេះពុំស្ថិតក្នុងតំបន់បឹងទន្លេសាប។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទនេះក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទនេះ បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទ វារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទ កូនត្រីពូជ | បរិមាណកូន ត្រីពូ(ក្បាល) | ខែ/ឆ្នាំ ចាប់ផ្ដើម | ខែ/ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្រាញ់ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ក្នុងស្រះចំនួន ១០ គ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បច្ចេកទេសចិញ្ចឹមត្រីក្រាញ់ជាលក្ខណៈគ្រួសារ<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១០ ស្រះ ទំហំ ៥មX ៦ ម ត្រីក្រាញ់ | ត្រីក្រាញ់ | ៤,០០០ | ១០/៩/១៩ | ៣០/៩/១៩ |

### គ.៦. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេក ទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

-ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល

-ជួយកាត់បន្ថយអត្រាចំណាកស្រុក

-ផ្តល់ចំណេះដឹងជំនាញនិងបច្ចេកទេស (ចិញ្ចឹមសត្វ កសិកម្មសមស្រប)

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ (ក្បាល) | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ១០គ្រួសារចិញ្ចឹមមាន់ ទា តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលចិញ្ចឹមជ្រូក<br>• អនុវត្តន៍ជាក់ស្តែង<br>• ជ្រើសរើសនិងធ្វើទ្រុង<br>• ទិញពូជនិងដាក់ពូជចិញ្ចឹម តាមដានត្រួតពិនិត្យ | មាន់ ទា ក្នុងស្រុក | ៦ក្បាល x ១០គ្រួសារ =៦០ក្បាល | ៣/១/២០ | ២០/១/២០ |
| ៥គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ។ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលចិញ្ចឹមជ្រូក<br>• អនុវត្តន៍ជាក់ស្តែង<br>• ជ្រើសរើសនិងធ្វើទ្រុង<br>• ទិញពូជនិងដាក់ពូជចិញ្ចឹម តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក ២ក្បាល/គ្រួសារ | ១០ក្បាល | ៥/៥/២១ | ៣០/៥/២១ |

### គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

**គោលចំណាប**

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល

- កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១៥ គ្រួសារ នឹងឧបត្ថម្ភដោយអង្គការ FAO | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ការរៀបចំក្រុមសន្សំ<br>• ជ្រើសរើសប្រធាន អនុប្រធាន និងហិរញ្ញិក<br>• បង្កើតគោលការណ៍ និងបទបញ្ញាផ្ទៃក្នុង<br>• ផ្ដល់ទុន<br>• បណ្ដុះបណ្ដាលពីការរៀបចំឯកសារ និងថវិកា ត្រួតពិនិត្យតាមដាន | ៧/១២/១៧ | ២០/១២/ ១៧ |

## គ.៨. ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍

ពេលបច្ចុប្បន្ន សហគមន៍នេសាទសាមគ្គីស្ទឹងកំបុត្របានគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅកន្លែងអន្លង់តាជន ដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ក្នុងគោលបំណង៖

- បង្កើនប្រាក់ចំណូលដែលជួយស្ដួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ និង
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| ការបង្កើតកន្លែងកំសាន្តនៅអន្លង់តាជន របស់សហគមន៍នេសាទ | • ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍<br>• ការរៀបចំក្រុមសម្រាប់អនុវត្ត<br>• បង្កើតគោលការណ៍ និងបទបញ្ញាផ្ទៃក្នុង<br>• បណ្ដុះបណ្ដាលពីការរៀបចំឯកសារនិងថវិកា<br>• ត្រួតពិនិត្យតាមដាន | ៧/២/២១ | ១៥/០១/ ២២ |

## គ.៩. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទគួរត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំ

បោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនីតិវិធីដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ
- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ។

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០១៨ | ២០១៨ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០១៩ | ២០១៩ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២០ | ២០២០ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២១ | ២០២១ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២២ | ២០២២ |

## គ.១០. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត(៥ឆ្នាំ) | | | | | តម្លៃប៉ាន់ស្មាន (គិតជារៀល ) | ប្រភពទុន |
|---|---|---|---|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | | |
| ផ្សព្វផ្សាយពីច្បាប់ | ខណ្ឌរដ្ឋបាល | ៤ | ៤ | ៤ | ៤ | ៤ | ៤.០០០.០០០ | ថវិកាឃុំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | ផលផល | | | | | | | កម្មវិធី EU |
| ផ្សព្វផ្សាយលទ្ធផ្លិកៈនិងបទ បញ្ញាផ្ទៃ | គណៈកម្មការ | ៣ | ៣ | ៣ | ៣ | ៣ | ២.២៥០.០០០ | ថវិកាឃុំ ដៃគូអភិវឌ្ឍ |

## គ.១១.ផែនការសង់ស្នាក់ការសហគមន៍នេសាទសាមគ្គីស្ទឹងកំបុត្រ

ពេលបច្ចុប្បន្ន សហគមន៍នេសាទសាមគ្គីស្ទឹងកំបុត្រពុំទាន់មានស្នាក់ការសម្រាប់គណៈកម្មការសហគមន៍នេសាទធ្វើការនៅឡើយទេ ដែលអាចបង្កការលំបាកក្នុងពេលបំពេញការងារគណៈកម្មការសហគមន៍នេសាទ ក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម ។ ដូច្នេះ គណៈកម្មការសហគមន៍នេសាទនេះមានផែនការសាងសង់ស្នាក់ការសហគមន៍មានដូចខាងក្រោម៖

| ប្រភេទសកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ ស្មាន(រៀល) | ប្រភពទុន |
|---|---|---|---|---|
| ផែនការសាងសង់ស្នាក់ការ | ២០១៧ | ២០២២ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| តុ កៅអី និងទូឯកសារ | ២០២២ | ២០២២ | ២.០០០.០០០ | |
| សរុប | | | ៣០.០០០.០០០ | |

## គ.១២.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលនិងចំណាយពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ចំណូលពីក្រុមសន្សំប្រាក់ ១ក្រុម កន្លែងកំសាន្តធម្មជាតិ និងការធ្វើទស្សនកិច្ចរបស់ភ្ញៀមមកក្នុងសហគមន៍នេសាទ ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោះ

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (រៀល) |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ២០១៧ | ២០២២ | ១.៥៧៧.៥០០ |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០១៧ | ២០២២ | ១.០០០.០០០ |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ប្រមូលប្រាក់បដិភាគពីអ្នកនេសាទខាងក្រៅ | ២០១៧ | ២០២២ | ២៥០.០០០ |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិក | ២០១៧ | ២០២២ | ៥០០,០០០ |
| ភាគទានពីក្រុមសន្សំ | ប្រមូលប្រាក់បដិភាគពីក្រុមសន្សំ | ២០១៧ | ២០២២ | ២០០.០០០ |

| | | | | |
|---|---|---|---|---|
| សរសេរគម្រោងស្នើសុំ៖<br>-បដិភាគពីរាជរដ្ឋាភិបាល<br>-អំណោយពីសប្បុរសជន<br>- អង្គការដៃគូ | -បញ្ចូលផែនការទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>-សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០១៧ | ២០២២ | ១.០០០.០០០ |
| **សរុប** | | | | **៨,៥២៧,៥០០** |

### គ.១៣.ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ

សហគមន៍នេសាទមានសិទ្ធិរៀបចំបណ្តាញសហគមន៍នេសាទ ក្នុងគោលបំណងចែករំលែកព័ត៌មាន និងបទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាផលប្រយោជន៍រួមរបស់សហគមន៍នេសាទទាំងអស់។ បណ្តាញសហគមន៍នេសាទ គឺជាការចងសម្ព័ន្ធរួមគ្នារវាងសហគមន៍នេសាទដែលសម្របសម្រួល ដោយសមាជិកដែលបានជ្រើសរើសឆ្លងកាត់ការទទួលខុសត្រូវពីក្រុមសហគមន៍នេសាទ ។ បណ្តាញសហគមន៍នេសាទ មានកម្រិតថ្នាក់ស្រុក ខេត្ត តំបន់ និងថ្នាក់ជាតិ។

បណ្តាញសហគមន៍នេសាទនីមួយៗនឹងត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតជ្រើសរើសចេញពីប្រធានគណៈកម្មការសហគមន៍នេសាទពាក់ព័ន្ធដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ។ បណ្តាញសហគមន៍នេសាទនឹងមានតួនាទីជួយសម្របសម្រួល និងបានការគាំទ្រពីរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ។

បណ្តាញសហគមន៍នេសាទក្នុងគោលបំណង៖

- រំលែកព័ត៌មាន និងបទពិសោធន៍ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ
- បង្កើន ការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ ។

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ១ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | ៤ដង/១ឆ្នាំ | ២០១៧ | ២០២២ |
| ២ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | ១ដង/១ឆ្នាំ | ២០១៧ | ២០២២ |
| ៣ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ២០១៧ | ២០២២ |
| ៤ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ២០១៧ | ២០២២ |

### ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទសាមគ្គីអភិរក្សស្ទឹងកំបុត ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឲ្យការអនុវត្តផែនការទទួលបានជោគជ័យ ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលផលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង នឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារ ព្រែក ការកំណត់ឧបករណ៍នេសាទ ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងដៃគូដើម្បីសុំការគាំទ្រថវិកាសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគោការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីស្ទឹងកំបុត្រ រយៈពេល ០៥ ឆ្នាំ (ខែឧសភា ឆ្នាំ២០១៧-ខែឧសភា ឆ្នាំ ២០២២)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មាន ចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រេើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៣ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទ | ៧០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធ និងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដទៃ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការកែលំអផែននេសាទ** | •បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹក<br>•ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>•ទាក់ទាញភ្ញៀវទេសចរណ៍ និងផ្តល់ការងារដល់អ្នកខាងក្នុង | | | | |
| ២.១.ការស្តារបឹងភ្លៅដែលមានទំហំ ២ ហត | •ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>•ធ្វើការសិក្សាលើទំហំដែលត្រូវស្តារ<br>•ការស្តារបឹងភ្លៅ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| **៣.ការរៀបចំកន្លែងអភិរក្ស** | •ត្រីមេពូជ សត្វស្លាប និងសត្វល្មូនសំខាន់ៗ ត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ<br>•ប្រជាជនយល់ដឹងពីសារៈប្រយោជន៍ការអភិរក្ស និងចូលរួមថែរក្សា | | | | |
| ៣.១ បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្ស អន្លង់ស្វាយឈ្លប | •ចំនួន ៦ បង្គោលនឹងបានបោះនៅកន្លែងអភិរក្ស<br>•មានផែនទីសំគាល់កន្លែងអភិរក្ស | ៥.០០០.០០០ | FAO<br>រាជរដ្ឋាភិបាល | ២០១៧ | ២០២២ |
| ៣.២ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | •ប្រជាជនមានការយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | | |
| ៣.៣ ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | •ចំនួន ១ ស្លាកផ្ទាំងប៉ាណូ នឹងត្រូវបានផលិតសម្រាប់ផ្សព្វផ្សាយ<br>•ផែនទី១ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | | | | |
| ៣.៤ ចុះល្បាតជាប្រចាំ | បទល្មើសនឹងថយចុះតាមរយៈការចុះល្បាតរបស់សហគមន៍ | | អង្គការដៃគូFAO | | |
| **៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ** | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹក<br>• ព្រៃលិចត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | ២០១៧ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក | សហគមន៍យល់ដឹងពីប្រយោជន៍និងថែរក្សាព្រៃលិចទឹក | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ៤.២.ដាំព្រៃលិចទឹកនៅកន្លែងអភិរក្ស **បឹងផ្តោល ១,៥ ហត** | • រៀបចំថ្នាលកូនឈើ<br>• ពិធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ ថែរក្សា និងការពារ | | | | |
| ៤.៣.ថែរក្សា និងការពារព្រៃលិចទឹកទំហំ **៥ ហត** | ដាក់ស្លាកសញ្ញាការពារ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ | | | ២០១៧ | ២០២២ |
| ៤.៣ ចុះល្បាតជាប្រចាំ | សមាជិកសហគមន៍ ចូលរួមទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក | ១.៥០០.០០០ | | | |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម (ការចិញ្ចឹមត្រីក្រាញ់តាមស្រះ)** | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | | | | |
| ៥.១.ជ្រើសរើសសមាជិកសហគមន៍ស្ម័គ្រចិត្ត | • សមាជិកស្ម័គ្រចិត្តចំនួន ១០ គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៥.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្រាញ់ | សមាជិកស្ម័គ្រចិត្តនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | | | | |
| ៥.៣.ធ្វើស្រះចិញ្ចឹមត្រីក្រាញ់ | ចំនួន ១០ ស្រះក្នុង១ស្រះមានទំហំ ៦ម x ៤ ម ត្រូវបានជីករួចរាល់ | | រាជរដ្ឋាភិបាល | | |
| ៥.៤.ការដាក់កូនត្រីដាក់ក្នុងស្រះ | ចំនួនកូនត្រីក្រាញ់ ២,៥០០ កូននឹងត្រូវបានផ្តល់ក្នុង១គ្រួសារ | | អង្គការដៃគូ | | |
| ៥.៥.ត្រួតពិនិត្យតាមដាន | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | ២.០០០.០០០ | សប្បុរសជន | ២០១៧ | ២០២២ |
| **៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព** | • សមាជិកសហគមន៍បង្កើនប្រាក់ចំណូល<br>• ជួយកាត់បន្ថយអត្រាចំណាកស្រុក<br>• សមាជិកយល់ដឹងពីបច្ចេកទេសចំញ្ចឹមសត្វ | | | | |
| **៦.១.សមាជិកសហគមន៍ចិញ្ចឹមមាន់ និងទា** | ចំនួន ១០ គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមមាន់ និងទាជាលក្ខណៈគ្រួសារ | | | | |
| ៦.១.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ១០ គ្រួសារត្រូវបានជ្រើសរើស | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ៦.១.២ វគ្គបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមមាន់-ទា | ចំនួន ១០ គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់-ទា | | | | |
| ៦.១.៣ ការធ្វើទ្រុងចិញ្ចឹមមាន់ ទា | ចំនួន ១០ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម x ៤ ម ត្រូវធ្វើរួចរាល់ | | | | |
| ៦.១.៤ ផ្តល់ពូជ និងសំភារៈ | មាន់ ទាចំនួន ៦០ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | | | |
| ៦.១.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | ៣.៥០០.០០០ | | ២០១៧ | ២០២២ |
| **៦.២.សមាជិកសហគមន៍នេសាទចិញ្ចឹមជ្រូក** | ចំនួន ៥គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | | | | |
| ៦.២.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ៥ គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៦.២.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | ចំនួន ៥ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | | រាជរដ្ឋាភិបាល | | |
| ៦.២.៣ ការធ្វើទ្រុងចិញ្ចឹមជ្រូក | ចំនួន ៥ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម x ៤ ម ត្រូវធ្វើរួចរាល់ | ២.៥០០.០០០ | អង្គការដៃគូ | ២០១៧ | ២០២២ |
| ៦.២.៤ ផ្តល់ពូជ និងសំភារៈ | ជ្រូកមានចំនួន ១០ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | សប្បុរសជន | | |
| ៦.២.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | | | | |

| | | | | | |
|---|---|---|---|---|---|
| **៧.ការអភិវឌ្ឍន៍កម្មវិធីចំរុះ** | | | | | |
| ៧.១. បង្កើតក្រុមសន្សំប្រាក់ | សមាជិកសហគមន៍ស្ម័គ្រចិត្ត នឹងចងក្រងជាក្រុមសន្សំប្រាក់ | ៥.០០០.០០០ | គាំទ្រពីFAO រាជរដ្ឋាភិបាល សប្បុរសជន | ២០១៧ | ២០២២ |
| ៧.១.១ ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍ | សមាជិកស្ម័គ្រចិត្តចំនួន ២៥ នាក់ នឹងត្រូវបានផ្សព្វផ្សាយទស្សនៈ | | | | |
| ៧.១.២ ការបង្កើតក្រុមសន្សំ | សមាជិកស្ម័គ្រចិត្តចំនួន ១៥ នាក់ នឹងបានបង្កើតក្រុមសន្សំ | | | | |
| ៧.១.៣ បោះឆ្នោតជ្រើសរើសប្រធាន អនុ ប្រធាន | ប្រធាន អនុ ប្រធាន លេខា និងហិរញ្ញិកនឹងត្រូវបានបោះឆ្នោតជ្រើសរើស | | | | |
| ៧.១.៤ ការបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង នឹងត្រូវបានបង្កើតឡើង | | | | |
| ៧.១.៥ ការផ្តល់ទុន និងសំភារៈ | ទុន និងសំភារៈ នឹងត្រូវបានផ្តល់ក្រុមសន្សំប្រាក់ | | | | |
| ៧.១.៦ បណ្តុះបណ្តាលពីការរៀបចំថវិកា និងឯកសារ | សមាជិកចំនួន ១៥នាក់ នឹងបណ្តុះបណ្តាលពីការរៀបចំថវិកានិងឯកសារ | | | | |
| ៧.១.៧ ត្រួតពិនិត្យតាមដាន | ក្រុមសន្សំ នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលអនុវត្ត | | | | |
| **៨.ការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍** | • សមាជិកសហគមន៍រកប្រាក់ចំណូល<br>• បន្ថយអត្រាការប្រាក់ខ្ពស់ដែលខ្ចីពីឈ្មួញ<br>• សហគមន៍នេសាទអាចមានប្រាក់ចំណូល | | | | |
| ៨.១. បង្កើតកន្លែងកំសាន្តនៅអន្លង់តាជន | សមាជិកស្ម័គ្រចិត្តនឹងបង្កើតជាក្រុមកន្លែងកំសាន្តសហគមន៍ | ៤.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០១៧ | ២០២២ |
| ៨.១.១.ផ្សព្វផ្សាយពីកន្លែងកំសាន្តដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធ ត្រូវបានផ្សព្វផ្សាយពីកន្លែងកំសាន្តសហគមន៍ | | | | |
| ៨.១.២ បោះឆ្នោតជ្រើសរើសប្រធាន អនុ ប្រធាន | ប្រធាន អនុ លេខា និងហិរញ្ញិកនឹងជ្រើសរើសសម្រាប់កន្លែងកំសាន្ត | | | | |
| ៨.១.៣ ការបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនឹងរៀបចំសម្រាប់កន្លែងកំសាន្ត | | | | |
| ៨.១.៤ ការរៀបចំទីកន្លែងកំសាន្តសហគមន៍ និងសំភារៈ | ទីកន្លែងកំសាន្តសហគមន៍ នឹងត្រូវបានសង់ និងបំពាក់សំភារៈ | | | | |
| ៨.១.៥ បណ្តុះបណ្តាលពីថវិកា និងឯកសារ | បច្ចេកទេសរៀបចំឯកសារ នឹងបានបណ្តុះបណ្តាល | | | | |
| ៨.១.៦ ត្រួតពិនិត្យតាមដាន | នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលអនុវត្ត | | | | |
| **៩.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង<br>• បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | | | | |
| ៩.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ របាយការណ៍និងលិខិតរដ្ឋបាល នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ | ២០១៧ | ២០១៧ |
| ៩.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | | ២០១៨ | ២០១៨ |
| ៩.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០១៩ | ២០១៩ |
| ៩.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០២០ | ២០២០ |
| ៩.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២១ | ២០២១ |

| | | | | | |
|---|---|---|---|---|---|
| | | | សប្បុរសជន | | |
| **១០.ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋាន ពាក់ព័ន្ធនឹងវិស័យជលផល** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | | | | |
| ១០.១.ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យជលផល | ច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធជាមួយវិស័យជលផល នឹងត្រូវបានផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ២.០០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | ២០១៧ | ២០២២ |
| ១០.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង នឹងផ្សព្វផ្សាយ | ៧៥០.០០០ | សប្បុរសជន | ២០១៧ | ២០២២ |
| **១១.ការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | |
| ១១.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិក សហគមន៍ | ១.៧៥០.០០០ | រាជរដ្ឋាភិបាល | ២០១៧ | ២០២២ |
| ១១.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | អង្គការដៃគូ | ២០១៧ | ២០២២ |
| ១១.៣.**គម្រោងស្នើសុំ៖** បដិភាគពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន **និង**អង្គការដៃគូ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៤.៧៥០.០០០ | សប្បុរសជន | ២០១៧ | ២០២២ |
| **១២.ផែនការសាងសង់ស្នាក់ការសហគមន៍** | | | | | |
| ១២.១.សាងសង់ស្នាក់ការសហគមន៍ | ស្នាក់ការរបស់សហគមន៍នេសាទត្រូវបានសាងសង់ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល | ២០២១ | ២០២១ |
| ១២.២.តុ កៅអី និងទូឯកសា | សម្ភារៈកៅអី និងទូឯកសារ ត្រូវបានបំពាក់ | ២.០០០.០០០ | អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២២ |
| **១៣.ការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលប្រជុំផ្សេងៗ** | | | | | |
| ១៣.១.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | បណ្តាញសហគមន៍នេសាទថ្នាក់ស្រុកនឹងត្រូវបានរៀបចំប្រជុំ | ២០០.០០០ | រាជរដ្ឋាភិបាល | ២០១៧ | ២០២២ |
| ១៣.២.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | បណ្តាញសហគមន៍នេសាទថ្នាក់ខេត្តនឹងត្រូវបានរៀបចំប្រជុំ | ៤០០.០០០ | អង្គការដៃគូ | ២០១៧ | ២០២២ |
| ១៣.៣.ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំ | ៨០.០០០ | សប្បុរសជន | ២០១៧ | ២០២២ |
| ១៣.៤.ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | គណៈកម្មការសហគមន៍នឹងចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ៨០.០០០ | | ២០១៧ | ២០២២ |
| **គម្រោងចំណាយសរុប** | | **៥៣,៩៦០,០០០** | | | |

## តារាងកម្មវិធីការងារប្រចាំ រយៈពេល ០៥ ឆ្នាំ (ខែឧសភា ឆ្នាំ២០១៧-ខែឧសភា ឆ្នាំ ២០២២)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | ២០១៨ | | | ២០១៩ | | | ២០២០ | | | ២០២១ | | | ២០២២ | | |
| | ឧសភា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ឧសភា |
| ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | |
| ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| ៥.ការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | |
| ៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | | | | | | | | | | | | | | | | | |
| ៧.ការអភិវឌ្ឍន៍កម្មវិធីចំរុះ | | | | | | | | | | | | | | | | | | |
| ៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ៩.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ១០.ផ្សព្វផ្សាយពីច្បាប់ផលជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | |
| ១១.ផែនការបង្កើតស្នាក់ការ សហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ១២. ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ១៣.ការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលប្រជុំផ្សេងៗ | | | | | | | | | | | | | | | | | | |

សូមគោរពជូន

លោកមេឃុំកំពង់ស្វាយ

ដើម្បីជូនពិនិត្យ និងសម្រួល

ធ្វើនៅ....ថ្ងៃទី១៨....ខែមករា ឆ្នាំ២០១៧.

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ:០៤៧/១៧

បានឃើញ និង គោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផល

កំពង់ស្វាយលើ

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃទី១៨ ខែ០១......ឆ្នាំ២០១៧

**មេឃុំ**

**ជា_យឿន**

បានឃើញ និង គោរពជូន

លោកនាយផ្នែករដ្ឋបាលជលផល

ផាត់សណ្ដាយ

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃទី១៨...ខែមករា..ឆ្នាំ២០១៧

**នាយសង្កាត់រដ្ឋបាលជលផល**

**កំពង់ស្វាយលើ**

បានឃើញ និង គោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃទី១៨...ខែមករា.ឆ្នាំ២០១៧

**ន. នាយផ្នែករដ្ឋបាលជលផលផាត់សណ្ដាយ**

លេខ:០១២/១៧

បានឃើញ និង គោរពជូន

លោកនាយអធិការដ្ឋានរដ្ឋបាលជលផលជើងបឹងទន្លេសាប

ដើម្បីជូនពិនិត្យ និងសម្រួល

..........កំពង់ធំ......ថ្ងៃទី..១៨....ខែ.មករា.ឆ្នាំ ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប៉ែន_វណ្ណារិទ្ធ**

លេខ.០០១/.....អជស

បានឃើញ និង គោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ

.................ថ្ងៃទី ១៩.......ខែ.មករា.ឆ្នាំ ២០១៧

**ន. នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប**

លេខ២០៩៤..ជជ

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ .ថ្ងៃទី១៧...ខែកុម្ភៈឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**